រាជធានីភ្នំពេញ, ថ្ងៃទី១០/៤/៩៧

# របាយការណ៍
# ស្តីអំពីសកម្មភាពចុះស្រាវជ្រាវ
# ឯកសារទាក់ទងអំពើឧក្រិដ្ឋកម្ម
# របស់បន ប៉ុល ពតនៅស្រុកពញាក្រែក
# ខេត្តកំពង់ចាម លើកទី២

កាលពីថ្ងៃទីប្រាំពីរ ខែមេសា ឆ្នាំមួយពាន់ប្រាំបួនរយកៅសិបប្រាំពីរ មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយនឹងបណ្ណាសារដ្ឋានតំកល់ឯកសារ បានចាត់តាំងសហការីមួយក្រុមមានគ្នា ៣នាក់ ដឹកនាំដោយលោក **ស៊ិន ឃិន** និងលោក **ហាក់ សុផល** សមាជិក និងអ្នកបើកបររថយន្ត ។

ផ្អែកតាមរបាយការណ៍របស់ការិយាល័យវប្បធមិស្រុកពញាក្រែក និងផ្អែកតាមរបាយការណ៍ក្រុមស្រាវជ្រាវឯកសារចុះលើកទី១ នាយកមជ្ឈមណ្ឌលបានពិនិត្យឃើញថា ស្រុកពញាក្រែកនេះមានអំពើឧក្រិដ្ឋកម្ម ទូទាំងឃុំចំណុះស្រុក មានច្រើន ដែលក្រុមយើងចុះលើកទី១ ធ្វើការបានតែមួយចំនួន ដោយពេលវេលាខ្លី ហេតុនេះយើងក៏ចុះស្រាវជ្រាវជាក់ស្តែងម្តងទៀតនៅស្រុកនោះ ។

* <u>ការងារទំនាក់ទំនងរដ្ឋបាល</u>

លើកទី២នេះ យើងមិនបានទៅទាក់ទងឯកឧត្តមអភិបាលខេត្តទៀតទេ ដោយលោកបានឯកភាពរួចហើយ ដូច្នេះយើងទៅទាក់ទង ចៅហ្វាយស្រុកពញាក្រែកតែម្តង ក្រុមស្រាវជ្រាវបានធ្វើដំណើរតាមផ្លូវជាតិលេខ៦ និងបន្តពីខេត្តតាមផ្លូវជាតិលេខ៧ ទៅដល់ស្រុកម៉ោង ១១:៣០ ។

នៅម៉ោង១៤:០០ យើងបានទៅកាន់មន្ទីរស្រុកទំនាក់ទំនង សុំកំលាំងនគរបាល ២នាក់ ការពារ និងមន្ត្រីវប្បធមិ ១នាក់ តែមិនបានសំរេច ដោយគ្មានមន្ត្រី នគរបាល មិននៅកន្លែង ។

មន្ត្រីរដ្ឋបាលរបស់ស្រុក ទៅទាក់ទងស្នងការនគរបាល យើងរង់ចាំអស់ ២ម៉ោង មិនបានកំលាំងសហការ ដូច្នេះយើងសំរេចចុះទៅមណ្ឌលឧក្រិដ្ឋកម្មតាមឯកសារមានស្រាប់ ។

នៅម៉ោង ១៦:៣០ យើងបានធ្វើដំណើរទៅកាន់ <u>មណ្ឌលឧក្រិដ្ឋកម្ម ភូមិអណ្តូត ឃុំកណ្តោលជ្រុំ</u> ចន្លោះព្រំប្រទល់ ភូមិត្រពាំងសង្កែ ឃុំស្រឡប់ ស្រុក ខេត្ត ដដែល ។ ចម្ងាយផ្លូវពីសាលាស្រុកមកផ្លូវបត់ចូល ១៤គីឡូម៉ែត្រ បត់ស្តាំដៃ ចូលដល់ទីតាំងចម្ងាយ ២គីឡូម៉ែត្រ សរុប ១៦គីឡូម៉ែត្រ នៅទិសខាងត្បូងសាលាស្រុក ។

មណ្ឌលឧក្រិដ្ឋកម្មនេះឋិតនៅភូមិភាគបូព៌ា តំបន់២១ សម័យ **ប៉ុល ពត** ហើយទីតាំងរួមមាន

១- មន្ទីរសន្តិសុខ

២- គុក

ជាកន្លែងដ៏ធំឈ្មោះថា មន្ទីរសន្តិសុខ ភូមិភាគបូព៌ា ប្រចាំតំបន់ ២១ ។ ទីតាំងនោះពីអតីតកាលជាចំការដូង **មេព្រៃម័ន** ហៅថា **ព្រៃយាយនែត** ។ ពីមុនគឺសុទ្ធតែដើមដូង ។ ( មុនសម័យ **ប៉ុល ពត** ) ។

ពត៌មាននោះដឹងតាមរយៈប្រជាជនក្នុងភូមិ ដូច្នេះយើងបានទៅជួបលោកមេភូមិ ឱ្យគាត់ជួយរកសាក្សីបាន ២នាក់ ឈ្មោះ **គឹម ណុល** អាយុ ៤៧ឆ្នាំ សម្បុរខ្មៅ កំពស់ ១,៦០ម៉ែត្រ សម័យ **ប៉ុល ពត** នៅភូមិអណ្ដោត ឃុំកណ្ដោលជ្រុំ ស្រុកខេត្ត ដដែល ។ បច្ចុប្បន្នអនុប្រធានក្រុម ភូមិ ឃុំស្រុក ដូចគ្នា ។

យើងនិងសាក្សីព្រមទាំងមេភូមិបានទៅដល់ទីតាំងសន្តិសុខ គុក កន្លែងសម្លាប់តែម្ដង បានពិនិត្យផ្ទាល់ឃើញថា អណ្ដូង រណ្ដៅសាកសព ឆ្អឹង ខោអាវ មាននៅសេសសល់ខ្លះៗទីនោះពិតប្រាកដមែន ។ បន្ទាប់ពីបានដឹងច្បាស់ យើងបន្តសួរពត៌មានពីសាក្សីរូបនោះដូចតទៅ :

សាក្សីបានបំភ្លឺថា គុក-សន្តិសុខ កន្លែងសំលាប់នៅទីនោះបានកសាងឡើងនៅឆ្នាំ១៩៧៥ តៗមកដល់ឆ្នាំ១៩៧៩ មុនឆ្នាំ១៩៧៥ ធ្វើនៅស្រុកមេមត់ ពួក **ប៉ុល ពត** រើរុះមកនៅទីនោះ ១៩៧៥ គុកនោះធំបំផុត មានអគ្គិសនី ភ្លឺព្រោងព្រាត ពេលយប់ ។ មេគុកឈ្មោះ **យឹម សុគី** និង **អា តេន** ។ ( បាត់ខ្លួន) ។ ទីនោះពីមុនសុទ្ធតែព្រៃ ។ បរិវេណ ព្រៃ ដី សម្លាប់ ២គីឡូម៉ែត្រ បួនជ្រុង និងរណ្ដៅសាកសពធំ៤រណ្ដៅ និងរណ្ដៅតូច ចំនួន ១៨៥រណ្ដៅ ។

ចំនួនសាកសព ស្លាប់នៅទីនោះមាន ១១២៩៤ នាក់ ។ អដ្ឋិធាតុគ្មានសារៈមន្ទីរពិតទេ ។ យោងតាមឯកសាររបស់មន្ទីរវប្បធម៌ស្រុក ។

+ អំពីប្រភេទជនរងគ្រោះស្លាប់នៅទីនោះ :

ជនរងគ្រោះដែលស្លាប់នៅទីនោះមានពីរដំណាក់កាលគឺ :

+ ទី១ នៅឆ្នាំ១៩៧៥-៧៦ គឺទាហ៊ាន ប៉ូលីស ប៉េអ៊ឹម គេញ គយ សិស្ស និស្សិត មន្ត្រីរដ្ឋការស៊ីវិល គ្រូបង្រៀន និងគ្រួសារ កូនចៅ ទាំងអស់ ។ អ្នកទាំងអស់នោះដឹកមកទាំងឡានៗ យកមកទុកសិនម៉ោង ១៤:០០ ទៅ ១៥:០០ ចាប់ផ្ដើមសម្លាប់ វិធីសម្លាប់ ចាក់មេក្រូ និងបុកអង្រែត្បាល់ អោយពួសួររំពង ។

+ ទី២ ជនរងគ្រោះស្លាប់ទីនោះពីឆ្នាំ១៩៧៧-៧៨ និងដើមឆ្នាំ១៩៧៩ គឺពួក **ប៉ុល ពត** មាន កងតូច កងធំ ប្រធាន អនុ សហករណ៍ កងទ័ព ពួកសន្តិសុខ ដែលនៅភូមិភាគបូព៌ា តំបន់ ២១ ពួកនិរតីខ្លះ ពួកខាងបូព៌ាខ្លះ ដែលវាតែងតាំង អ្នកដាច់ខាត អោយសម្លាប់ពួកបូពា ។

សាក្សីបន្ថែមថា ពួកបូព៌ាស្លាប់នេះគឺ ស្លាប់ទាំងគ្រួសារ ដូចអ្នកជំលៀសដែរ ( អ្នកជំលៀសចេញពីទីក្រុង ។ មិនតែប៉ុណ្ណោះសម្លាប់ប្រជាជន ប្រមូលយកពីស្រុកស្ទឹងត្រង់ ស្រុកមេមត់ ក្រូចឆ្មា ស្រុកតំបែរ និយាយរួមទូទាំងខេត្តកំពង់ចាម ។

អំពីទារុណកម្ម : ពេលសួរចំលើយចងខ្សែពួរ មែកឈើ យោលទម្លាក់ និងដកក្រចកដៃ និងក្រចកជើង ។

តាមការប៉ាន់ស្មានសាក្សីអំពីរណ្តៅជនសម្លាប់រួចទម្លាក់ និងចំនួនសាកសព ពីព្រោះគាត់បានឃើញគេលួចគាស់ខ្មោចយកមាស នៅឆ្នាំ១៩៧៩-១៩៨០ ឃើញពាសពេញទីនេះ ឆ្អឹងគោស៊ីអស់ហើយ ។

សាក្សីបានបន្ថែមថា ជនរងគ្រោះមកកាន់ទីនេះពុំមានវាសនាបានរួចខ្លួន ឬ រស់ ១នាក់ណានោះទេ ។ សាក្សីមានរូបថត និងថតខ្សែអាត់ កាសែតទុកឯកសារហើយ ។

នៅថ្ងៃទី ៨/៤/៩៧ នៅវេលាម៉ោង ៩:០០ ខ្ទះ ១០នាទី យើងបានធ្វើដំណើរឆ្ពោះទៅមណ្ឌលឧក្រិដ្ឋកម្ម ស្ទឹងតូច ក្នុងភូមិស្ទឹងតូច ឃុំកក់ ស្រុកពញាក្រែក ខេត្តកំពង់ចាម ។

ដំបូងយើងបានជួបលោកមេឃុំ **នូ ណាន** រួមដំណើរ និងសេនាជន ២នាក់ នៅទីនោះចម្ងាយពីសាលាស្រុក ១០គីឡូម៉ែត្រ និងពីផ្លូវជាតិលេខ៧ ប្រហែល ៤គីឡូម៉ែត្រ ។

នៅទីនោះយើងបានជួប លោកតា **នៅ ណូ** អាយុ ៥៦ឆ្នាំ សក់ស្កូវមួយៗ កំពស់ ១,៦៥ម៉ែត្រ សម្បុរស ពាក់អាវក ( មូរអាវចិន) ។ លោកតានេះពួក **ប៉ុល ពត** ចាប់ចងដៃ យកទៅសម្លាប់ ប៉ុន្តែគាត់រត់រួចទាំងចំណងដៃ សម័យ **ប៉ុល ពត** គាត់នៅភូមិពន្លៃ ឃុំកក់ តួនាទីពេលនោះ សហករណ៍ បច្ចុប្បន្នប្រជាជនភូមិពន្លៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តកំពង់ចាម ។

មូលហេតុ គេយកគាត់ គ្នាគាត់ ៦នាក់ទៀត ទៅសម្លាប់ គេចោទថា ខ្មាំងយួន បំរើនយោបាយឱ្យយួន ។ គ្នាគាត់ ៨នាក់ស្លាប់ទាំងអស់រត់រួចតែគាត់ម្នាក់ទេ ដោយគាត់ដោះចំណងដៃរួច ពេលចងគាត់តំឡើងដៃធំ វាចងរាងតឹងតែក្រោយមក ធូរបន្តិច គាត់រត់ គេបាញ់ពីក្រោយចំរុះ ក្រោយមកគេតាមគាត់រហូតព្រលប់ ទើបវារកលែងឃើញ ។ សាក្សីរូបនោះ គាត់បន្ថែមទៀតថា ក្រោយៗមកទៀតគាត់បានឃើញពួកវា ប្រមូលប្រជាជន រត់ចូលព្រៃមកសំលាប់ ដោយវាភូតកុហកថា ពួក **សោ ភឹម** ក្បត់ជាតិមិនអោយប្រជាជនស៊ីឆ្អែត ធ្វើបាបប្រជាជន អង្គការថ្នាក់លើមិនអោយធ្វើដូច្នោះទេ ដូច្នេះវាសម្លាប់តែជនក្បត់ទេ ចំពោះបងប្អូនអង្គការមិនយកទោសពៃរ៍អ្វីទេ អ្នករត់ចូលព្រៃ ត្រូវត្រឡប់មកភូមិកំណើតវិញ

ប្រជាជនជឿពួកវាក៏មកវិញ ពួកវានិយាយថា អង្គការផ្លាស់ប្តូរទីលំនៅក៏អោយឡើងរថយន្ត យកទៅ គឺយកទៅសំលាប់នៅស្ទឹងតូច ព្រៃស្ទឹងតូច ចម្ងាយពីសាលាស្រុក ៧គីឡូម៉ែត្រ ចម្ងាយពីព្រំដែនវៀតណាម ៦គីឡូម៉ែត្រ ឋិតក្នុងឃុំកក់ ។

ដូច្នេះហើយក្រុមស្រាវជ្រាវឯកសារ បានធ្វើដំណើរទៅពិនិត្យមណ្ឌលឧក្រិដ្ឋកម្ម ស្ទឹងតូច ព្រៃស្ទឹងតូច ឋិតក្នុងភូមិស្ទឹងតូច ឃុំក្រែក ស្រុក-ខេត្ត ដដែល ។ យើងទៅដល់ទីនោះនៅម៉ោង ១០:៣៥ ។ នៅទីនោះយើងបានស្រាវជ្រាវរកឃើញ :

សាក្សីទី១ : ឈ្មោះ **នន ណន** អាយុ ៤៤ឆ្នាំ កំពស់ ១,៧០ម៉ែត្រ សម្បុរស សក់ស្កូវមួយធ្មេញមិនទាន់បាក់ សម័យ **ម៉ុល ពត** រស់នៅភូមិពន្លៃ ឃុំកក់ (បច្ចុប្បន្នឃុំកក់) ។ តួនាទី គ្រូបង្រៀនកុមារតូចៗ បច្ចុប្បន្ននៅភូមិ ឃុំដដែល ។ គាត់រួចជីវិតដោយរត់ចូលទៅប្រទេសវៀតណាម នៅឆ្នាំ១៩៧៧ លុះ ១៩៧៩ មកវិញ ។

សាក្សីរូបនេះរួមដំណើរទៅពិនិត្យរណ្តៅសាកសព នៅទីតាំង ព្រៃស្ទឹងតូចនោះ យើងបានឃើញជាក់ស្តែង រណ្តៅនៅទីនោះមាន ៣កន្លែង ទី១មាន ៤រណ្តៅ ទទឹង ៣ម៉ែត្រ បណ្តោយ ៤ម៉ែត្រ ជំរៅ ២ម៉ែត្រ រណ្តៅ ទី២ ចម្ងាយ ២០០ម៉ែត្រ ក្រោយផ្ទះឈ្មោះ **នឹម ចាន** មានរណ្តៅចំនួន ១ ជំរៅ ២ម៉ែត្រ-៣ម៉ែត្រ បួនជ្រុង សាកសពវាយសម្លាប់ពេញ ។ នៅកន្លែងទី៣ មានរណ្តៅ៤ទៀត ចម្ងាយពីរណ្តៅខាងលិច ៥០០ម៉ែត្រ បត់ស្តាំចូល ព្រៃ ១០០ម៉ែត្រ ។ នៅទីនោះព្រៃស្រ៊ុប មានរណ្តៅធំ ៤ រណ្តៅតូច ជាលេណដ្ឋានយោធា វាយសម្លាប់ពាសពេញ ឆ្នាំ១៩៧៩ សាក្សី ឈ្មោះ **សេន យ៉ុន** បច្ចុប្បន្នគាត់ នៅភូមិស្ទឹងតូចនោះ ឃើញមុនគេនៅឆ្នាំ ១៩៧៩ ។ ទីនោះផ្លូវលេខ ២៤ ។ សម្លាប់ក្បែរផ្លូវគ្រាន់តែចូលជ្រៅ ១០០ម៉ែត្រ ប៉ុណ្ណោះ ។

ចំនួនជនរងគ្រោះស្លាប់នៅទីនោះប្រហែល ១.៨០៣នាក់ (មួយពាន់ប្រាំបីរយបីនាក់) ។ ហើយប្រភេទជនរងគ្រោះយកមកសម្លាប់ទីនោះដឹករថយន្ត ពីភូមិឫស ភូមិពន្លៃ ភូមិទឹកយង់ និងប្រជាជនមូលដ្ឋានចាស់ទូទាំងស្រុកពញាក្រែក ។

សាក្សីរូបនេះគាត់បន្ថែមប្រាប់យើងថា អ្នកត្រូវយកមកសម្លាប់ទីនោះ គ្រួសារ ប្រពន្ធកូន ពួកធ្វើការអោយ **ម៉ុល ពត** ដែរ តែប្តី រត់ចូលព្រៃ ប្តីធ្វើទ័ពនៅបូព៌ា និងប្រជាជនមូលដ្ឋានខ្លះ ឯរណ្តៅខ្លះសម្លាប់សុទ្ធតែទិសបូព៌ា តែម្តង មូលហេតុដឹង គឺឆ្នាំ១៩៧៩ ឃើញខោអាវទ័ព ពីដុងទឹក ខ្សែក្រវ៉ាត់ ស្បែកជើងកង់ឡានល្អៗ ដែលគេបើកជូនទ័ព (តែទ័ពនោះគឺទ័ពបូព៌ា) ។

វិធីដឹកទាំងឡានៗទៅសម្លាប់ ពួកវាច្រើនតែនិយាយកុហកថា អង្គការអោយផ្លាស់បងប្អូនទៅនៅកន្លែងថ្មី សហករណ៍ថ្មី ឬសហជីព កម្មករចំការកៅស៊ូ ហូបឆ្អែត មួយថ្ងៃ ៣ដង ។ ប៉ុន្តែធាតុពិត ឡើង

លើរថយន្តដាក់ខ្នោះជើងជាប់គ្នាតែម្តង ។ ពួកវាថាខ្លាចរត់ទើបដាក់ខ្នោះ ដល់កន្លែងដោះលែងវិញហើយ ។ លុះដល់កន្លែងសម្លាប់ពួកឃាតករ ភ្ជង់កាំភ្លើងចងដៃម្តងមួយៗ រួចដោតជាខ្សែៗ បណ្តើរទៅសម្លាប់តែម្តង ។

នៅវេលាម៉ោង ១៤:៣០ យើងបានធ្វើដំណើរទៅមណ្ឌលឧក្រិដ្ឋកម្ម ឡូតិ៍លេខ ៣៧ ចំការកៅស៊ូ ឋិតក្នុងឃុំក្រែក នៅជើងភ្នំតាសិត ។ មណ្ឌលនេះយើងធ្វើដំណើរតាមផ្លូវជាតិលេខ៧ ទៅដល់បត់ឆ្វេងដៃ (នោះបើធ្វើដំណើរពីសាលាស្រុកទៅមេមត់) ។ ចម្ងាយពីសាលាស្រុក ៨គីឡូម៉ែត្រ ទៅទិសខាងកើតសាលាស្រុក ។

យើងបានទៅទីនោះជាមួយលោកមេឃុំក្រែក និង លោកមេភូមិធ្វើដំណើរទៅពិនិត្យជាក់ស្តែង នៅមណ្ឌលឧក្រិដ្ឋកម្ម ឡូតិ៍ ៣៧ ភូមិឡូតិ៍ ៣៧ ក្នុងចំការឡូតិ៍ ៣៧ ឃុំក្រែក ។ នៅទីនោះយើងបានជួប សាក្សីម្នាក់គឺលោក **ឃួន ឡេង** អាយុ ៤៥ឆ្នាំ សម្បុរស កំពស់ ១,៧០ម៉ែត្រ សក់ខ្មៅ ។ ជំនាន់ **ប៉ុល ពត** ធ្វើទ័ព នៅកងពលរបស់ **ចាន់ ចក្រី** ប្រចាំការនៅស្រុកកៀនស្វាយ ខេត្តកណ្តាល ។

បច្ចុប្បន្ន ប្រធានភូមិតាសិត ឃុំក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម ។ គាត់បានចូលមករស់នៅស្រុកកំណើតនេះវិញ នៅឆ្នាំ១៩៧៩ នៅឆ្នាំដំបូងនោះគាត់បានមកឃើញរណ្តៅសាកសព នៅទីនោះឃើញខ្មោចហើមពោះ ឈាមក្បែរៗមាត់រណ្តៅ គាត់យកឈើចាក់ក្បែរៗមាត់រណ្តៅ ជំរៅ ៧តឹក ។ មិនទាន់ចាក់កណ្តាលផង ។

អំពី ចំនួនរណ្តៅ រណ្តៅសម្លាប់ទម្លាក់នៅក្នុងចំការកៅស៊ូ ឡូតិ៍៣៧ នេះគឺរណ្តៅ B៥២ មានជំរៅពី៦ម៉ែត្រ ទៅ ១០ម៉ែត្រ មាត់លើ ១២ម៉ែត្រ វាយសម្លាប់ពេញតែម្តង ។ គាត់បានពត៌មានពីប្រជាជនគ្នាគាត់ថា ជនរងគ្រោះស្លាប់នៅទីនោះមានច្រើនគឺកម្មករចំការកៅស៊ូ វាដឹកពីជប់ មេមត់ ដឹកម្តងៗ ១០ឡានធំៗ ទីនោះ គឺគ្មានសួរចំលើយអប់រំទេ យកមកសម្លាប់តែម្តង ។

ពួកឃាតករចាំទទួលសម្លាប់ វាបានសង់ផ្ទះ១ នៅក្បែរព្រៃចំការកៅស៊ូ ខាងលិចនោះចាំតែទទួលសម្លាប់តែម្តង ។ សម្លាប់នៅឆ្នាំ១៩៧៨ ។

តាមពត៌មានសាក្សីអោយដឹងថា វិធីសម្លាប់មុនដំបូងកុហកថា ផ្លាស់ប្តូរ ពីចំការកៅស៊ូមួយ ទៅមួយផ្សេងទៀត ដូច្នេះពួកវា ដឹកទាំងឡាន១ដូចធម្មតា ។

ពួកមេឃាតករសម្លាប់នៅទីនោះគឺពួកមកពីភូមិភាគកណ្តាល ។ គ្មានពួកមូលដ្ឋានបូពាំនោះទេ ។ ចំនួនជនរងគ្រោះ ស្លាប់នៅទីនេះប្រហែល ៧,២៨៦នាក់ (នៅមណ្ឌលឧក្រិដ្ឋកម្មឡូតិ៍៣៧នេះ) ។

**<u>សេចក្តីសន្និដ្ឋាន</u>**

ការចុះស្រាវជ្រាវអំពើឧក្រិដ្ឋកម្មនៅស្រុកពញាក្រែកនោះបាន ៣ឃុំ បាន៣មណ្ឌលឧក្រិដ្ឋកម្ម ហើយយើងបានពិនិត្យលើតួលេខ ស្លាប់មានច្រើន១ជាងគេទើបយើងចុះ ។ យើងមិនអាចចុះបានច្រើនកន្លែងលើសនេះបានទេ មូលហេតុ ផ្លូវពីសាលាស្រុកទៅដល់ទីតាំងឆ្ងាយ ចម្ងាយផ្លូវពីមណ្ឌលឧក្រិដ្ឋកម្ម ១ផ្សេងទៀតឆ្ងាយ ឯផ្លូវលំបាក ។

ការចុះទៅដល់មណ្ឌលឧក្រិដ្ឋកម្មនិមួយ១ជាក់ស្តែង និងស្រង់បានពតិមានជាក់ស្តែង ជាការល្អ ពីព្រោះបានជួបសាក្សី និងប្រជាជនផ្ទាល់អាចដឹងការពិតបានជាងឯកសារវិប្បធម៌ទៅទៀត ។

<u>ឧទាហរណ៍</u> : មានកន្លែងខ្លះឃើញរណ្តៅ៩ ប៉ុន្តែ ឯកសារដាក់ថា ៥រណ្តៅ នេះការស្រង់ជាប្រយោល ហើយដូច្នេះតួលេខ យើងគិតទៅតាមរណ្តៅ និងពតិមានពីសាក្សីដឹងឮ និងឃើញ ។

ការចុះទៅចូលព្រៃស្ងាត់ ជនបទ ដាច់ស្រយាលនេះ គឺយើងហ៊ានប្រឈមមុខពីរ ទី១ ចំពោះខ្មាំង **ម៉ុល ពត** (បើសិនមាន) ទី២ ចំពោះពួកចោរប្លន់ ជាក់ស្តែង ស្រុកពញាក្រែក ទ័ពរត់ចូលព្រៃ ប្រមូលគ្នីគ្នាបាន ១២នាក់ បច្ចុប្បន្នប្រជាជនមិនហ៊ានដេកផ្ទះ ប្លន់បាញ់សំលាប់ ពេទ្យស្រុកម្នាក់ថ្មី១ និងបាញ់គោទាក់គោ ប្រជារាស្ត្រស៊ី និងលក់ទៅវៀតណាម ។

ដូច្នេះទៅទីនោះលើកនេះ យើងមិនជួបចៅហ្វាយស្រុក គេទៅខេត្តប្រជុំ យើងទាក់ទងរដ្ឋបាលស្រុក សុំកងការពារនគរបាលស្រុកមិនបាន ដូច្នេះបង្ខំចិត្តចុះទៅមូលដ្ឋានរកមេឃុំ សេនាជនធ្វើការជាមួយយើង ដូច្នេះស្ថានភាពមូលដ្ឋានខ្លះមិនមែនងាយស្រួល ដូច១គ្នានោះទេ ។ បច្ចុប្បន្ននេះ បែបបទរដ្ឋបាលគេច្រើនស្តាប់បញ្ជាខ្សែរយៈជំនាញ បណ្តោយត្រង់១ពីមេបញ្ជាការថ្នាក់លើរបស់គេ ។

<u>ឧទាហរណ៍</u> : ប៉ូលីសស្តាប់ស្នងការប៉ូលីសខេត្ត ។ល។ ដូច្នេះស្រុករដ្ឋបាលដែនដី (ពិបាក) ។ ដូច្នេះការងារចុះស្រាវជ្រាវឯកសារនោះ គឺសំខាន់ណាស់ និងធំធេងណាស់ដែរ មិនមែនជាការធម្មតានោះទេ គឺជាការទទួលខុសត្រូវ ប្រវត្តិសាស្ត្រ របស់ប្រទេសមួយដ៏សំខាន់ដែរ ។

**<u>សំណូមពរ</u> :**

លោកនាយកផ្តល់មតិ ជាជំនួយ តើយើងធ្វើយ៉ាងណាអោយកិច្ចការរបស់យើងប្រសើរជាងនេះទៅទៀត ។

ភ្នំពេញ,ថ្ងៃទី ១០/៤/៩៧

អ្នកធ្វើរបាយការណ៍

**ស៊ិន ឃិន**